# ការសំភាសន៍របស់លោកយាយ "ហុក ណម"

កៈ អ្នកសំភាសន៍មាន អ៊ុំ កន្និកា ខៈ អ្នកត្រូវគេសំភាសន៍មាន ហុក ណម

គៈ អ្នកចូលរួមក្នុងការសំភាសន៍ រី សិត់

កៈ ជំរាបសួរអ៊ុំស្រីហើយអ៊ីក
ជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ុំស្រីដែលបានអនុញ្ញាតអោយនាងខ្ញុំនេះធ្វើការសំភាសន៍អ៊ុំស្រីទាក់ទងទៅនិងជីវប្រវត្តិរបស់អ៊ុំស្រីផ្ទាល់ផងដែរ
ហើយការសំភាសន៍មួយនេះគឺធ្វើឡើងដោយសាលាសកលវិទ្យាល័យប៊ីវ៉ាយយ៉ូ(BYU)
ដោយសារតែសកលវិទ្យាល័យពួកយើងអ៊ីណាស់អ៊ុំមានបំណងចង់ថែរក្សានូវជីវប្រវត្តិរបស់អ៊ុំស្រីទុកសំរាប់កូនចៅជំនាន់ក្រោយដើម្បីពួកគេអាចទុកជាបទពិសោធន៍និងជាទុនមួយសំរាប់ដឹកនាំជីវិតរបស់គេចឹងអ៊ីណាស់អ៊ុំហើយនាងខ្ញុំជាអ្នកសំភាសន៍នេះនាងខ្ញុំឈ្មោះអ៊ុំ កន្និកា
ហើយការសំភាសន៍មួយនេះគឺធ្វើឡើងក៏ដូចជាធ្វើចេញពីម្ដុំភូមិភ្នំក្រោមហើយកាលបរិច្ឆេតគឺនៅថ្ងៃទី 8 ខែមីនា ឆ្នាំ2018
ហើយបន្ទាប់ពីខ្ញុំសំភាសន៍ក៏ដូចជាថតសំលេងលោកអ៊ុំចប់ដូចជាសុំការអនុញ្ញាតពីអ៊ុំស្រីដើម្បីខ្ញុំអាចដាក់សម្លេងរបស់អ៊ុំស្រីចូលទៅក្នុងគេហទំព័ររបស់ពួកយើងដែលមានឈ្មោះថា (www.cambodia.noralhistory.by.edu)
ផងដែរហើយដូចជាពួកយើងនិងទៅជួបអ៊ុំស្រីទាំងអស់គ្នា............ជំរាបសួរអ៊ុំស្រី...!

ខៈ ចា៎...!

កៈ តើអ៊ុំស្រីមានឈ្មោះអ្វីដែរ?

ខៈ ញ៉ុមឈ្មោះយាយណម...!

កៈ យាយណម.....?

ខៈ ចា៎...

កៈ
ចាំ..យាយណមចា..អ៊ុំស្រីដូចជាឈ្មោះពេញរបស់អ៊ុំស្រីមានឈ្មោះអ្វីទាំងត្រកូលទាំងអី
ទាំងអស់អ្នាំអ៊ុំមានឈ្មោះអ្វីដែរ?

ខៈ ឈ្មោះ...សួរពីក្រកូលអ្ហោះ?

កៈ ចាំ...!

ខៈ អឺ...ទាំងត្រកូលខ្ញុំឈ្មោះ ហុក ណម...

កៈ ហុក ណន..?

ខៈ ហុក ណម...!

កៈ ហុក ណម...! ?

ខៈ ចាំ...!

កៈ ចាំ...ចុះដូចជាលោកយាយមានឈ្មោះហៅក្រៅទេ?

ខៈ ហ៊ឺ..ហៅក្រៅគេហៅណមអញ្ចេះឯង...!

កៈ ហៅតា ណម ណម ចេះឯង...ណោះលោកយាយ?

ខៈ ចាំ...!

កៈ យាយណម
ចាំ..ចុះដូចជាតើឈ្មោះនេះតើលោកយាយដឹងទេថាជាឈ្មោះដែរឪពុកម្តាយដាក់អោយ
ឬក៏យាយតាជាអ្នកដាក់អោយដែរ?

ខៈ ខ្ញុំមិនដឹងដែរ តាដល់ដឹងក្តីម៉ោគេហៅតាអញ្ចេះឯង...! ប៉ុន្តែឈ្មោះ
ពីដើមម៉ោគឺឈ្មោះ ហុក សាវ៉ន ទេ...

កៈ ហុក សាវ៉ន...?  ឈ្មោះពីដើម...?

ខៈ ចាំ...ឈ្មោះពីដើមហើយពីដើមរៀនសាលាគេដាក់តោ សាវ៉នទេ...

កៈ លោកយាយប្តូរឈ្មោះរហូត...?

ខៈ ចាំ...ដល់ម៉ោហៅក្រៅគេហៅតែហុក ណម ចាចឹងបានថា...

កៈ ចាំ...អ៊ុំប្តូរបីឈ្មោះហើយណោះអ៊ុំណោះ...? (សើច)

ខៈ ចាំ..អញ្ចុះឯង...

កៈ ប្តូរតាមកន្លែងនីមួយៗ...

ខៈ ចាំ..ដរចូលរៀននោះណាំ...!

កៈ ចាំ...អ៊ុំតែឈ្មោះ

អ៊ុំពិរោះមែនទែន..ចុះអ៊ុំអញ្ចឹងអ៊ុំកាត់កូនចិនដែរទេ?

ខៈ ចិន...លោកពុក...ឪពុកខ្ញុំចិន តាកុងខ្ញុំយួន...!

កៈ ឡូយណាស់អ៊ុំអញ្ចឹងអ៊ុំកាត់បីសាសន៍..ណាំ..ចិន វៀតណាម ហើយនិងខ្មែរ...!

ខៈ ចា..និងហើយ...ម្តាយនិងខ្មែរ...!

កៈ ចាំ..ចុះឯអាយុរបស់អ៊ុំវិញអ៊ុំតើអ៊ុំមានព្រះជន្មប៉ុន្មានវស្សាហើយ?

ខៈ ខ្ញុំចិតប្រាំ...!

កៈ អ៊ុំចិតប្រាំហើយណោះអ៊ុំណោះ?

ខៈ ចាំ...!

កៈ ចុះអ៊ុំចាំទេអំពីថ្ងៃខែឆ្នាំកំណើតរបស់អ៊ុំអ្នាស?

ខៈ ចាំ...!

កៈ អ៊ូ.....!

ខៈ ខ្ញុំកើតខែចេត្រ ...

កៈ ខែចេត្រហើយ...

ខៈ ចា៎...ថ្ងៃអង្គារ៍...

កៈ ថ្ងៃអង្គារ៍ណោះអ៊ុំណោះ?

ខៈ ចា៎...!

កៈ ចុះឆ្នាំវិញអ៊ុំចាំទេ?

ខៈ ឆ្នាំរកា...!

កៈ ឆ្នាំរកា...អូ៎យ..អ៊ុំចាំច្បាស់ណាស..

ខៈ ខ្ញុំចាំ..ឆ្នាំរកា! ចា៎...

កៈចា៎...ល្អមែនទែន..!

ខៈ ប៉ុន្តែថាភ្នែកខ្ញុំមើលគេមិនច្បាស់...

កៈ ចា៎...នេះបើអ៊ុំមានវ៉ែនតាពាក់អ៊ុំច្បាស់ជាអាចមើលច្បាស់អ្នក...

ខៈ តែខ្ញុំអត់ចេះពាក់...

កៈ សើច...

ខៈ ពាក់ទៅវាធ្ងន់...ច្រមុះ..

កៈ សើច..អ៊ុំធ្ងន់ច្រមុះ...ដូចជាទីកន្លែងកំណើតវិញតើអ៊ុំកើតនៅទីណាដែរ?

ខៈ ខ្ញុំកើតនៅភ្នំក្រោម...

កៈ អ៎...កន្លែងដលអ៊ុំរស់នៅនេះម៉ងអ្ហោះអ៊ុំ?

ខៈ
ខ្ញុំកើតនៅទន្លេសាបប៉ិនតាទឹកដីម្ដុំភ្នំទាំងអស់និងឯងតែខ្ញុំកើតនៅទន្លេឯណោះខ្ញុំនៅឯទន្លេដូចថាជិក(ឪពុក)ខ្ញុំគាត់ចុះទៅលក់ចាប់ហួយនៅទន្លេដោះទៅខ្ញុំកើតនៅទន្លេ..

កៈ ចុះម្ដុំនិងគេហៅអីគេទៅអុំ ម្ដុំដែលអុំកើតនិងអុំចាំទេគេហាថាភូមិអីស្រុកអី...?

ខៈ អឺ...គេហៅទន្លេសាប...

កៈ គេហៅភូមិទន្លេសាបអញ្ចឹងអ្ហោះ?

ខៈ ចាំ..ភូមិទន្លេសាប...

កៈ ស្រុកសៀមរាបខេត្តសៀមរាប..?

ខៈ ចាស...! នោះឯង

កៈ អំ...ចាំអុំកើតនៅពេទ្យឬក៏នៅផ្ទះដែលអុំ? ខៈ
អឺ...ជំនាន់នោះមានពេទ្យម៉ោពីណាកូនសុទ្ធតែឆ្មបខ្មែរ..

កៈ ចឹងអ្ហោះអុំ...!

ខៈ ចាំ..!

កៈ អំ...ប្រហែលជាគេមកបង្កើតម្ដាយរបស់អុំស្រីនៅផ្ទះ...

ខៈ ចាំ...ខ្ញុំកើតនៅផ្ទះទេ...!

កៈ ចុះដូចជាអុំស្រីមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខៈ ខ្ញុំបងប្អូនប្រាំនាក់..

កៈ ប្រាំនាក់..ណោះអុំណោះ?

ខៈ ចាំ....!

កៈ ស្រីប៉ុន្មានប្រុសប៉ុន្មានដែរអុំ?

ខៈ ស្រីពីរប្រុសបី...!

កៈ ស្រីពីរប្រុសបី.....?

ខ៖ ចាំ..!

ក៖ ចុះអ៊ុំជាកូនទីប៉ុន្មានដែរទៅ?

ខ៖ ញ៉ុមកូនច្បងគេបង្អស់ទីមួយ.......

ក៖ អ៎...ចាំ..!

ខ៖ កូនទីមួយ...!

ក៖ ចាំ...អ៊ុំកូនទីមួយណោះអ៊ុំណោះ?

ខ៖ ចាំ...!

ក៖ ចុះដូចជាបងប្អូនឯទៀតគាត់នៅទីណាដែរសព្វថ្ងៃ?

ខ៖ នេះ...នៅជុំគ្នានេះឯងសព្វថ្ងៃ ខ្លះនៅនិងច្រមុះភ្នំ ខ្លះទៅនៅខាងគោកពីរ...

ក៖ អ៎...ចាំ..!

ខ៖ នៅខាងគោកពីរនោះមួយគ្រួសារ នៅភ្នំនេះម៉ាគ្រួសារ ខ្ញុំឯណេះម៉ាគ្រួសារ ឯណោះវាពីរគ្រួសារបីគ្រួសារ...

ក៖ ចាំ...អញ្ចឹងនៅសៀបរាមទាំងអស់គ្នា?

ខ៖ ចាំ...នៅសៀមរាបទាំងអស់គ្នាហើយភូមិផ្ទះនៅជាប់គ្នានិងឯងប្អូនៗញ៉ុម...!

ក៖ ចុះអ៊ីក..តើដូចជាពួកគាត់មានជីវភាពបែបណាដែរអ៊ុំដូចថាធូរធារ...

ខ៖ ពួកគេធូរធារអ្ហើយ...ក្រតែខ្ញុំមួយនេះឯង ក្រតែខ្ញុំនិងអាពៅគេមួយទេ ក្រខ្លាំងជាងគេ ផុតពីនោះគេធូរធារហើយ គេមានស្គាល់ដុល្លាម៉ឺនឯណោះអស់ហើយ ឡានគេម្នាក់បួនប្រាំផ្ទះក្បឿងគេក្រតែខ្ញុំនិងឯង...

ក៖ ចាំ...អ៎...តែគេរកមុខរបរអីណោះអ៊ុំណោះ?

ខ៖ គេគប់អាប៉ោងផង...គេដាក់កន្ត្រកហោះផង ហើយមួយទៀតនោះគេទិញត្រីគេចិញ្ចឹមគ្នាគេមានអស់ហើយវាក្រតាខ្ញុំនោះឯងពីរនាក់នេះឯង...

ក៖ អ៎...គេធូរធារអស់ហើយម្ហោះអ៊ុំ?

ខ៖ ចាំ...!

ក៖ ចុះគេមានគ្រួសាររៀងៗខ្លួនម្ហោះអ៊ុំ?

ខ៖ មានអស់ហើយ...គេមានរួចអស់ហើយ...

ក៖ ចុះពៅនិងក៏មានគ្រួសារដែរម្ហោះអ៊ុំ?

ខ៖ មានគ្រួសារទាំងអស់អត់មានណាអត់មួយទេ...!

ក៖ ចុះអ៊ុំនៅចាំឈ្មោះពួកគេទេអ៊ុំដែរថាប្អូនបន្ទាប់ពីអ៊ុំនិងឈ្មោះអីគេដែរ?

ខ៖ ឈ្មោះ...ចាំមើលខ្ញុំមិនទីមួយម្អាស...!

ក៖ ចាំ...!

ខ៖ មីស្រីនោះទីពីនិងឈ្មោះនឿម ...

ក៖ ឈ្មោះនឿម ចាំ...!

ចុះទីបីអ៊ុំស្រីក៏ប្រុស?

ខ៖ ទីបីឈ្មោះហ៊ន...

ក៖ ចុះស្រីក៏ប្រុសដែរអ៊ុំ?

ខ៖ ប្រុស...!

ក៖ ឈ្មោះហ៊ន...! ចុះទីបួនអ៊ុំ?

ខ៖ ទីបួនឈ្មោះអន្តិតហ្វូរ...

កៈ ឈ្មោះអន្ទិតហ្វរ....?

ខៈ ចាំ...! ហើយទីប្រាំនោះឈ្មោះអាហាក់...

កៈ ប្រុសដែរ...?

ខៈ ប្រុស...! អស់ហើយ...

កៈ អញ្ចឹងអ៊ុំហាក់និងគាត់ពៅគេ..?

ខៈ ចាំ...ពៅគេ!

កៈ តែពួកគាត់សុទ្ធតែមានកាងាររៀងៗខ្លួនអស់ហើយ?

ខៈ មានអស់ហើយ..!

កៈ តើអ៊ុំដូចជាធ្លាប់ជួបជុំគ្នាដើម្បីហូបអីជុំគ្នា?

ខៈ

ហ៊ឺ...ខែបុណ្យភ្ជុំអីគេម៉ោតើគេមកយកឥវ៉ាន់មកជូនខ្ញុំខែភ្ជុំអីណាស់មួយឆ្នាំម្តងទៅ...គេយកមកជូនទៅម៉ោតាំងចៅតាំងក្មួយតាំងកូនប្រពន្ធប្អូនបអីម៉ោទាំងអស់....

កៈ

ចាំ...ដោយសារផុតពីម្តាយឪពុកទៅគឺមានតាបងនិងឯងប្រៀបបានដូចជាម្តាយចឹងបុណ្យទានគាត់យកអីៗមកជូនអ៊ុំច្រើន...ចាំ!

ខៈ ចាំ...នោះឯង គេយកមកជូន..!

កៈ

តើអ៊ុំចាំសាច់រឿងទាក់ទងទៅនិងកាលពួកគាត់នៅពីក្មេងទេថាប្អូនពៅគាត់មានអត្តចរិកបែបណាឬក៏ប្អូនបន្ទាប់អ៊ុំគាត់មានអតចរិកបែបណាហើយគាត់ស្រលាញ់គ្នាបែបណាឬក៏អ៊ុំធ្លាប់ដូចជាធ្វើកិច្ចការអីជាមួយគ្នាដែរថាអ៊ុំចាំចឹងអ៊ីកណាស់?

ខ៖
អឺ...កូនអើយកុំអោយនិយាយឡើងវាមិនដែរត្រូវគ្នាទេតលូវនេះដល់តាតាំងពីតូចវាត្រូវគ្នាដល់គេមានគ្រួសាររៀងខ្លួនទៅចិត្តគេប្រែទាំងអស់..!

ក៖ អញ្ចឹងអ្ហោះអ៊ុំ...!

ខ៖ នោះឯង...!
គេមិនសូវដូចថាមិនសូវទាក់ទងគេទាក់ទងអ្វើយគ្រាន់តែថាវាមិនជិតស្និតយើងជាបងនោះណាស់...

ក៖ ចាំ...!

ខ៖ និងហើយគេមិនយល់ ដូចថាមានការអីឈឺជាអីបានគេរត់ម៉ោរកយើង
បើគេមានបានអីទៅគេស៊ីតាគេទៅណាំសចាំយើងទៅរកគេពឹងពាក់គេមិនបានទេ...!

ក៖ ចុះកាលនៅពីក្មេងពួកគាត់អត់អីទេណោះអ៊ុំណោះ?

ខ៖  ពីក្មេងមានអ្វីយ...!

ក៖ គាត់ស្រលាញ់គ្នាសាមគ្គីគ្នា...

ខ៖
ចាំ..ពីក្មេងមានអី..ចុះបើនៅក្រោមបន្ទុកម៉ែឪម៉ែឪគ្រប់គ្រងខ្លាចគ្នាទៅវិញទៅម៉ោដល់តាអត់ពីម៉ែពីឪទៅហើយមានគ្រួសាររៀងខ្លួនទៅក៏គេចិត្តផ្សេងៗពីគ្នាទៅណាស់គេមានគេមានតាគេទៅណាស់យើងអត់ក៏អត់តាយើងទៅហើយយើងខ្វះខាតអីទៅរកគេក៏គេថាគេអត់មានទៅហើយយើងក៏អត់ទៅៗក៏យើងខ្លួនពឹងខ្លួនទៅណាស់...

ក៖ ខ្លួនពឹងខ្លួនទៅ......

ខ៖
និងឯងខ្លួនពឹងខ្លួនទៅជាមួយកូនទៅកូនបានអោយហូបក៏ហូបទៅរហូតទាល់តាអាយុស្លាប់ទៅប៉ុនណោះឯង
វេទនាណាស់កូនហើយអាកាលដែលយើងនៅពីក្មេងមិញនិងយើងវានៅជាបងគេទៅ

គ្រាន់បើទៅដល់អាយុច្រើនទៅយើងគ្រប់គ្រងគេទាំងអស់ដូចថាអាមួយមានទុក្ខទៅនៅលើខ្ញុំ
អាមួយមានទុក្ខទៅនៅលើខ្ញុំៗដល់គេធំដុះច្រមុះដុះភ្នែកអស់ទៅគេមានគ្រួសារទៅយើងមានទុក្ខម្ដងគេអត់ដឹង...!

ក៖ ចាំ...!

ខ៖ តាមតែយើងចុះ
នេះបានថាខ្ញុំសព្វថ្ងៃខ្ញុំតូចចិត្តណាស់តូចចិត្តថាខំពីខ្លួននៅក្មេងក្រមុំម៉ោមានមាសមានប្រាក់ចែកបងចែកប្អូនដល់តាប្អូនធូរធារទៅភ្លេចអស់...

ក៖ ចាំ...!

ខ៖ កំសត់កម្រយ៉ាងណាំភ្លេចអស់..!
ភ្លេចអស់..គេដឹងតែថាខែភ្ជុំឡើងគេយកមកជូនម្ដងទៅប៉ុនណោះឯងខែភ្ជុំឡើងម្ដងទៅ...ឈឺក៏ឈឺតែយើងទៅអ៊ុយក៏អ៊ុយតាយើងទៅណាស់ពឹងគេក៏គេមិនដឹងចឹងបានថាវាគួរឈឺចាប់...បានផ្ដាំកូនសារក្រោយអាណាមានមិនបាច់ជួយអាណាទេ បាច់ជួយទេ..!
ព្រោះទុកជាគំរូហើយអោយវាដាបសឹមថា...មើលតាថាអ៉ក...ក្រាំងអីអានោះសឹមអោយវាទៅកុំអោយជួយវាតាជួយវាទៅ...មើលមើសតាវាធូរធារទៅវាភ្លេចអស់យើងមានទុក្ខយ៉ាងណាក៏វាមើលមិនឃើញ
បានថាវាលំបាកណាស់វាឆ្អែតណាស់កូនឆ្អែតហើយលាងអាចន៍ច្របាច់នោមក្ដៅខ្នងរងរំពាត់ដោយសារតាវាទៅក៏ឥតអំពើកេរ្តិ៍អាករអីយើងក៏អត់បានបានតាអាអ្នកពៅៗគេបានតាអាប្អូនគេទៅយើងក៏អត់ទៅ...!

ក៖ និយាយបងគរហត់ជាងគេតែទ្រព្យបានទើលើពៅច្រើន...

ខ៖ នោះឯង...! ហើយអាខុសក៏ខ្លាំងជាងគេ...

ក៖ ចាំ...គេវ៉ៃដោយសារប្អូនច្រើនជាងគេម្លោះអ៊ំ...

ខ៖ អ៊ែនិងឯង

បានយប់មិញញ៉ុមនិយាយប្អូនថ្លៃគេដែលប្ដីគេងាប់និងណាស់ងាប់ចងកអីល្ងវណេះឯង...

ក៖ អ៎..ថ្មីៗនិងដែរ

ខ៖

ទើបនិងធ្វើបុណ្យមួយរយថ្ងៃនេះឯងគេមកអញ្ជើញខ្ញុំប្រពន្ធគេនោះណាំគេមកអញ្ជើញខ្ញុំថាចែខ្ញុំអញ្ជើញចែឯងចូលរួមបុណ្យមួយរយថ្ងៃអោយប្ដីខ្ញុំ...ខ្ញុំធ្វើបុណ្យអោយប្អូនចែឯងញ៉ុមថាអើធ្វើទៅឯងមានលុយធ្វើអោយវាក៏ធ្វើទៅចុះយើងថាមិចមិននិយាយអញ្ចុះអ្ហាស

ឯងមានទ្រព្យធ្វើអោយវាក៏ធ្វើទៅហើយបានមៈបានផលតាខ្លួនឯងទៅមៈផលនិងមិនដែលបាត់ទេប៉ិនតាអញមិនដឹងទៅរួចឬក៏មិនរួចទេទៅរួចទៅៗរៀបចំអោយកូនទៅគិតអញ្ចេះឯងភ្នែកក៏ងងឹតដើរក៏មិនរួចហើយបទជើងបទដៃបានតាគេលើកគេអីគេអូសគេអីទៅមុជទឹកមុជអី...

ក៖ ចា៎..អ៊ុំ..!

ខ៖ វេទនាណាស់...!

ក៖ ចុះប្អូនរបស់អ៊ុំដែលថាចងកនិងប្អូនបង្កើតមែនអ៊ុំ?

ខ៖ និងឯង... វាទាស់ទេញគ្នាប្ដីប្រពន្ធវាមិនដឹងរឿងអ៊ុយទេគេ...។

ក៖ កូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ មើសទីមួយ....វាទីពីរទីបីទីបួន...មើសខ្ញុំទីមួយ មីនាងទីពីមីហ៊ានទីបីអន្តិតហ្ងរទីបួនងាប់អាទីបួនចងកនោះ។

ក៖ ឈ្មោះអន្តិតហ្ងរនិងអ្ហោះអ៊ុំ?

ខ៖ ចា៎...!

កៈ គាត់ចងកដោយសារមូលហេតុអីអ៊ុំដឹងទេ?

ខៈ អត់ដឹងទេ...! ប្រពន្ធគេម៉ោល្ងាចមិញគេថាអត់មានរឿងអីផង...!
មានតារឿងទាស់គ្នានិងឯង គេខឹងគេប៉ិនណោះឯង។

កៈ គាត់គិតខ្លីដល់ហើយណេះអ៊ុំណេះ?

ខៈ វាគំនិតវាខ្លី...! ឡានអ៊ុយៗដីផ្ទះអីៗនៅនិងគេទាំងអស់នៅនិងគេឥតអំពើទៅ...!

កៈ ចាំ...!

ខៈ អញ្ចឹងបានថាគំនិតវាខ្លីណាស់មីអូន គំនិតវាខ្លីណាស់...!

កៈ ចុះអ៊ុំដូចជាមានចៅប៉ុន្មាននាក់ហើយអ៊ុំ?

ខៈ មានបី...! អានេះមួយមីទូចមិញមួយទៅរៀនមួយ..!

កៈ សុទ្ធតែរៀៗទាំងអស់...!

ខៈ ចាំ...រៀន!

កៈ អានេះៗថ្ងៃនេះវាស្អីគេអាថ្ងៃសិទ្ធនារីអីគេនោះៗវាអត់ទៅរៀន...! សើច..

កៈ ចាំ...ប្រាំបីមីនា...

ខៈ អត់បានរៀនទេ...អើយចឹងបានថាវាលំបាកណាស់...

កៈ ចាំ...ចុះដូចជាអ៊ុំស្រីមានកូនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ មីមិញនោះ...? កូនពីរ..!

កៈ អត់ទេអ៊ុំកូនបង្កើតរបស់អ៊ុំអ្នាស!

ខៈ អុំ..ខ្ញុំនេះ...!

កៈ ចាំ...!

ខ៖ កូនស្រីមានតាវាមួយមីមិញនិងឯង...

ក៖ អំ...!

ខ៖ ប្រុសពីរស្រីមួយញ៉ុមមានតាបីនាក់ទេញ៉ុមកូនបី...!

ក៖ អំ...អ៊ុំមានតាបីនាក់ទេ...! ប្រុសពីរស្រីមួយ..!

ខ៖ ចាំ...

ក៖ ចា..ចុះអ៊ុំអាចប្រាប់ឈ្មោះពួកគេបានទេថាកូនអ៊ុំឈ្មោះអីខ្លះ?

ខ៖ បានតាសកូនច្បងឈ្មោះសុង...

ក៖ ចុះកូនទីពីរឈ្មោះអ៊ុំ?

ខ៖ ទីឈ្មោះស៊ន ចាំមីមិញនិងឈ្មោះស៊ន ហើយកូនទីបីនោះឈ្មោះសន...

ក៖ ឈ្មោះសន...?

ខ៖ ចាំ......!

ក៖ អញ្ចឹងអ៊ុំបានកូនប្រុសស្រីប្រុស...?

ខ៖ នោះឯង..បីប៉ុនណោះឯង...!

ក៖ ចុះដូចជាម្ដាយរបស់អ៊ុំស្រីមានឈ្មោះអីដែរអ៊ុំ?

ខ៖ ឈ្មោះយាយរស់......!

ក៖ ឈ្មោះយាយរស់...?

ខ៖ ចាំ.....!

ក៖ ចាំ...ចុះដូចជាកាលគាត់ចែកឋាននិងគាត់អាយុប៉ុន្មានដែរអ៊ុំ?

ខ៖ កាលម្ដាយញ៉ុមស្លាប់គាតអាយុប៉ែតសិបបួនឆ្នាំ។

កៈ អូ...ចាំប៉ែតសិបបួនឆ្នាំបានគាត់ស្លាប់......

ខៈ និងឯង......

កៈ ហើយចុះស្រុកកំណើតគាត់វិញ?

ខៈ គាត់កើតនៅឯនេះឯង...!

កៈ អ៎..គាត់កើតនៅឯនេះឯង?

ខៈ ចាំ...! ភូមិឯណោះឯង...!

កៈ ភូមិភ្នំក្រោមនេះដែរ...!

ខៈ ចាំ...!

កៈ គាត់ចែកឋានដោយសារមូលហេតុអីដែរអ៊ុំ?

ខៈ គាត់ចាស់ឈឺជម្ងឺមនុស្សចាស់...!

កៈ គាត់ឈឺជម្ងឺមនុស្សចាស់ណោះអ៊ុំណោះ?

ខៈ ចាំ...!
ហើយបើជិក(ឪពុក)ញ៉ុមគាត់ស្លាប់មុនម្តាយញ៉ុម...ឪពុកញ៉ុមកាលគាត់ខូចនិងអាយុហុកសិបប្រាំមួយឆ្នាំ(66ឆ្នាំ)..!

កៈ ជិកអ្ហោះអ៊ុំ?

ខៈ ចាំ...!

កៈ ឪពុកគេហៅ(ជិក)ណោះអ៊ុំណោះខ្មែរចិន?

ខៈ ចាំ...! ខ្លះគេហៅជិកខ្លះគេហៅទា...!

កៈ ចាំ...កាលចែកឋាននិងហុកប្រាំមួយណោះអ៊ុំ...?

ខៈ ចាំស....! ណោះសល់រូបថតគាត់តាមួយទេណ្ហក..!

កៈ
អ៊ុំមានចាំទេអំពីអត្តចរិករបស់ម្តាយរបស់អ៊ុំស្រីថាម្តាយរបស់អ៊ុំគាត់គឺជាមនុស្សបែបណាដែរអ៊ុំ?

ខៈ អូយគាត់ល្អណាស់ អ្នកណាមួយក៏រាប់អានគាត់ គាត់ល្អណាស់...! ហើយជិតខ្ញុំក៏ដោយញាត្តិសន្តានណាគឺថាឃើញគាត់អត់បានទេគាត់ធូរគោតធារមែនប៉ុនាត់អត់ចេះឆ្មើងមិនដែរវ៉ៃកូនដល់ម៉ោបានកូនម៉ោកូនដូចស្អីគេចេះឯងវ៉ៃរិកញុំមធ្វើជាបងគេពីដើមម៉ោញ៉ុមធ្វើគ្រាន់បើដែរកុំតែថាឥលូវខ្លួនញ៉ុមចាស់ទៅញ៉ុមអត់...! ញ៉ុមបំភ្លេចចោល...

កៈ ចាំ...អ៊ុំចុះម្តាយរបស់អ៊ុំគាត់កាចក៏ស្លូតដែរអ៊ុំ?

ខៈ អូ...ស្លូតណាស់តែបើជិកញ៉ុមកាចណាស់ហើយ...!

កៈ ឪពុករបស់អ៊ុំកាច...?

ខៈ ចាំ...កាច..!

កៈ អ៊ុំខ្លាចឪពុកជាងណោះអ៊ុំណោះ?

ខៈ ចាំ...គាត់កាចមែនទែន...!

កៈ គាត់កាចនិងព្រោះថាគាត់វ៉ៃអ៊ុំឬក៏គ្រាន់តែគាត់មើលមុខអ៊ុំៗខ្លាចតែម្តង...?

ខៈ អូ...គ្រាន់តែឃើញមុខគាត់ខ្លាច...!

កៈ មុខគាត់កាចណាស់អ្ហោះអ៊ុំ?

ខៈ ញ៉ុមខ្លាចមែនទែនបើគាត់វ៉ៃគ្មានជានាទេងាប់និងរស់ស្មើគ្នា...!

កៈ តែទាល់តែថាមានរឿងធំបានគាត់...

ខៈ ទាល់តែមានរឿងធំគាត់មិនចេះវ៉ៃទេ...!

កៈ
គាត់មិនដែរចេះតែរ៉ែទេ...ចុះម្តាយរបស់អ៊ុំកាលគាត់នៅរស់គាត់ប្រកបមុខរបរអីគេដែរ?

កៈ គាត់មានធ្វើអីគាត់...!
តាំងពីក្រមុំម៉ោគាត់ដឹកតាមោងដល់តាគាត់បានជិកខ្ញុំម៉ោគាត់ស្រណុករហូតគាត់មាន
ធ្វើអីទេ...!

កៈ ចាំ..!

ខៈ ហើយជិកញ៉ុមគាត់លក់ចាប់ហួយ...!

កៈ គាត់លក់ចាប់ហួយ..ច្រើនទេអ៊ុំ?

ខៈ លក់ច្រើន...!
គាត់លក់ចាប់ហួយកាលនិងនៅម្តុំនិងមានតាគាត់និងឯងលក់តាគាត់និងឯងទៅដល់ពេ
លគាត់ចាស់ខ្លួនគាត់ឡើងមកនៅលើវិញរួចគាត់ទិញស្រូវគាត់ទិញស្រូវរាប់ពាន់ថាំង
ទៅណាំសបើគិតចំនួនទៅ...!

កៈ ចាំ...គាត់ទិញយកធ្វើអីទៅអ៊ុំ?

ខៈ គាត់ទិញទៅលក់...!

កៈ គាត់ជាឈ្មួញកណ្តាលគាត់អ្នកយកមកលក់...!

ខៈ
ចាំ...ដូចថាគាត់ទិញពីអ្នកស្រែម៉ោគាត់ដាក់ជង្រុកទុកទៅដល់តាចប់អ្នកស្រែទៅឈ្មួញ
គេម៉ោឡានពីរបីម៉ោៗដឹកទៅក៏វាល់លក់ទៅ...!

កៈ ចំនេញឆ្នាំ.ណេះអ៊ុំណេះ?

ខៈ ចុះមានអី....

កៈ គាត់ធូរធារដេសអ៊ុំ?

ខៈ ចាំ...គាត់ធូរធារតាស...!

កះ អញ្ចឹងអ៊ុំអត់សូវពិបាកទេណោះអ៊ុំណោះ?

ខះ ព្រោះកាលនិងឪពុកម្ដាយអ៊ុំមានលុយផ្គត់ផ្គង់អោយ...

ខះ អត់មានពិបាកអ៊ុទើបបងបានប្ដីមកទើប៉ុមស្គាល់...!

កះ ចាំ...អ៊ុំ.

ខះ ញ៉ុមវេទនាមែនទែន...!

កះចុះអ៊ុំដូចជាចាំសាច់រឿងឪពុកម្ដាយរបស់អ៊ុំទេថាគាត់ធ្លាប់និទានប្រាប់អ៊ុំថាគាត់ពីក្មេងគាត់ធ្លាប់លំបាកអញ្ចេកៗៗ...?

ខះ អឺ...កាលពីក្មេងគាត់មានពិបាកអីគាត់ គាត់សប្បាយចិត្តតារហូតនិង...!

កះ អ្ហឹងអ្ហោះអ៊ុំ...?

ខះ នោះឯងគាត់មានកើតទុក្ខអ៊ុយគាត់ព្រោះឪពុកគាត់មាននោះ...

កះ អញ្ចឹងគាត់អត់សូវពិបាកទេ...

ខះ គាត់អត់មានពិបាកទេ...! ម៉ែខ្ញុំទោះជាគាត់ដឹកមោងអីមែន...ក៏គាត់អត់លំបាក..! ផ្ទះគាត់មានធំស្គឹមស្គៃនៅរស់នៅរបស់គាត់ស្រួល...!

កះ ចាំ...អ៊ុំអញ្ចឹងគាត់អត់សូវលំបាកអីទេតាមដៃរអ៊ុំដឹង...?

ខះ គាត់អត់មានពិបាកអីទេ..!

កះ ចាំ..ដូចជាតើស្វាមីរបស់អ៊ុំមានឈ្មោះអីគេដែរ?

ខះ ឈ្មោះសូរ...!

កះ  ឈ្មោះសូរ..?

ខះ ចាំ...!

កះ គាត់ព្រះជន្មប៉ុន្មានហើយអ៊ុំ?

ខ៖ អាកាលខូចនេះគាត់ព្រះជន្មហាសិបជាងគាត់គ្រូបង្រៀន..!

ក៖ អ៎...គាត់មានមុខរបរជាគ្របង្រៀន..

ខ៖ មានមុខរបរជាគ្របង្រៀន...!

ក៖ គាត់គ្រូបង្រៀនផ្នែកភាសាអីគេដែរបង អ៊ុំដឹងទេ?

ខ៖
ភាសាខ្មែរយើងនេះឯងដែរបង្រៀនដូចថាកនក្មេងអ៊ុយ.បង្រៀននៅណា..យើងពីដើមមិញយើងមានីមួយទីពីអ៊ុយយើងមានតែអាត្រែតអាទិពីដើមព្វថ្ងៃបានគេមានថ្នាក់ទីមួយទីពីទីបីមានទីប្រាំពីប្រាំបីអឺណា គេប្រែប្រួល...

ក៖ គេប្រែប្រួលហើយណោះអ៊ុំណោះ?

ខ៖ នោះឯង...! គាត់បង្រៀន

ក៖ អញ្ចឹងអឺ...ស្វាមីរបស់អ៊ុំគាត់ធ្លាប់ជាគ្រ...?

ខ៖ ចាំ...!

ក៖ អញ្ចឹងពេលគាត់ឈប់ គាត់អាត្រែតអីទៅអត់មានអ្នកណាគេមកបង់អី...ដូចថា..!

ខ៖ គ្មានទេ..!

ក៖ លុយអត្រែតអីអញ្ចឹងអ្ហាស..?

ខ៖ អត់ទេ...គាត់បង្រៀនដូចថាប្រាក់ខែក៏គ្មានអីក៏គ្មាននោះឯង...!

ក៖ ស្មាគចិត្តអ្វីអ៊ុំ...?

ខ៖ អី..បង្រៀននិងបង្រៀនតាំពីនៅបួស
កាលគាត់បួសជាសង្ឃដល់តាសឹងម៉ោហើយក៏នៅតែបង្រៀនទៀតប៉ុនតែគ្មានប្រាក់ខែប្រាក់ង៉ែអ៊ុយទេ...

ក៖ អញ្ចឹងគាត់ធ្លាប់បួសជាសង្ឃ?

ខ៖ ចាំ...!

ក៖ អ...ចាំគាត់បង្រៀនតាំងពីគាត់នៅកំលោះបួសជាសង្ឃមកម្លេះ..

ខ៖ និងហើយ...!

ក៖ ដល់ពេលគាត់សឹកម៉ោហើយមានប្រពន្ធហើយក៏នៅតែបង្រៀនដែរ...!

ខ៖ នោះឯងបង្រៀនដែរ..!

ក៖ អញ្ចឹងបើគាត់បង្រៀនអត់បានលុយអញ្ចឹងចុះតើជីវភាពគ្រួសាររបស់អ៊ុំពិបាកទេអ៊ុំ?

ខ៖
ហ៊ឺ...និយាយមិនពិបាកលំមិច..ជំនាន់នុងមិនដឹងវាយ៉ាងមិចទើបគេមិនអោយប្រាក់ខែ..

ក៖ អ្ហឹងម្លោះអ៊ុំ...?

ខ៖
នុងឯងគេអត់អោយប្រាក់ខែ...តេសគេហៅគាត់ទៅបង្រៀនគាត់ចេះតាទៅបង្រៀនទៅ
វាល់ៗល្ងាចមកវិញញ៉ាំបាយខ្លួនឯងទៅ.

ក៖
ចាំ...អញ្ចឹងអ៊ុំគិតយ៉ាងមិចទៅអ៊ុំ...ព្រោះស្វាមីរបស់យើងអត់មានលុយចូលផ្ទះអញ្ចឹងអ៊ុំគិតយ៉ាងមិចទៅ?

ខ៖ មានគិតយ៉ាងមិច..ខ្ញុំរកខ្លួនខ្ញុំ..!

ក៖ អ៊ុំរកអីដែរអ៊ុំ..ពេលនិង?

ខ៖ ខ្ញុំជួញជំនួញ ខ្ញុំលក់ដូរតាំងពីអង្ករតាំងពីទឹកស្អីថាស្អីក៏ត្រូវលក់ក៏លក់ដែរ..!

ក៖ អ៊ុំលក់សឹងតែគ្រប់មុខហើយណោះអ៊ុំណោះ?

ខ៖
ដល់តាពេលញ៉ុមម៉ោបានប្តីហើយប្តីខ្ញុំងាប់ទៅខ្ញុំចុះទៅនៅទន្លេខ្ញុំចាក់បញ្ញេវខ្ញុំធ្វើជ្រក់ខ្ញុំ

កែលតលក់បង្អែមគ្រប់មុខចិញ្ចឹមបានកូនធំអស់នេះឯងឡើងលែងដើររួចលែងរកប ណ្តោយ ដើរអត់រួចលែងរកកើត...!

កៈ អោយកូនគាត់ចេញជួយធ្វើការម្តង...

ខៈ នោះឯង...!

កៈ ចុះអ៊ុំដូចជាបានដូចជាអោយកូនថៅរៀនបានខ្ពង់ខ្ពស់ដែរទេអ៊ុំ...?

ខៈ ទេ...មិនសូវបានប៉ុន្មានទេ...!
កាលណោះមានបានរៀនឯណារៀនតាបងគេបានចេះច្រើនអាប្អូនអត់បានរៀនទេ ព្រោះខ្ញុំបានអោយរៀនតែបន្តិចបន្តួចទៅខ្ញុំខឹង...

កៈ ថីបានខឹងអ៊ុំ?

ខៈ
ថា...ចុះបើបងប្អូនមាមីងគេអត់អើពើគេមិនអ៊ុតនុនគ្នាៗទៅនៅក៏មិនដឹងឯណាបាយឯ ណាទឹកទៅខ្ញុំខឹងញ៉ុមថាកូនឯងអីលូវឈប់ទៅបើកូនឯងទៅរៀនអត់មានអាណាមើល ប្អូនបានអ្នកណាមើលប្អូនម៉ែទៅរកចិញ្ចឹមបើលោកពុកខ្វិននោះ...។

កៈ ចាំ...អញ្ចឹងស្វាមីរបស់អ៊ុំខ្វិននិងតាំងពីអាយុប៉ុន្មានដែរ?

ខៈ ខ្វិនគិតទៅប្រាំឆ្នាំខ្វិនតាំងពីសែសិបប្រាំឡើងហាសិបគត់បានគាត់ស្លាប់...។

កៈ គាត់ខ្វិនដោយសារអីដែរអ៊ុំ?

ខៈ ទេមិនដឹងថារឿអ៊ុយទេណាំ..ស្រាប់តែគ្រុនៗៗៗក៏ងាប់ដៃងាប់ជើងទៅ...!

កៈ មិនមែនស្លាប់មួយជំហៀងខ្លួនទេ?

ខៈ
ងាប់ត្រឹមនេះឯងទៅក្រោមដៃមួយជំហៀងនេះរស់តែមួយជំហៀងទេនាងទៅបើយើង ខ្មែរនេះគេថាយើងត្រូវរបស់គេ...!

កៈ អូយ...អាណិតគាត់អ្ហា៎...ណោះអ៊ុំណោះ?
គាត់ធ្លាប់តែដើរធឺ..ដល់ពេលអោយគាត់ម៉ោសុខៗចឹងមិនដឹងថាគាត់ពិបាកប៉ុនណា...!

ខៈ ពិបាកនិងឯង...!

កៈ អញ្ចឹងតើអ្នកណាជាអ្នកទទួលបន្ទុកថែទាំគាត់ទៅអ៊ុំ?

ខៈ មានឯណាមានតែកូនពីរបីនាក់នេះនិងឯងវានៅមើល ព្រោះខ្ញុំជាប់ទៅរកស៊ី...

កៈ អ៎...អញ្ចឹងបានទ្រង់មិនបានរៀននិងអ្ហា៎...!

ខៈ ចា៎...ខ្ញុំចុះទៅរកស៊ីបាត់នៅនិងភ្នំកាលគាត់ខ្វិនញ៉ុមនៅលើគោកនៅនិងដីម៉ែខ្ញុំ...

កៈ ចា៎...!

ខៈ
ដល់តែខ្ញុំទុកចោលទៅគេខ្ញុំចុះទៅរកនៅទន្លេចឹងទៅណាស់ហើយមួយសប្តាហ៍ញ៉ុមឡើងមកម្តងយកប្រាក់មកទិញអានេះអានោះអោយក៏កូននិងនេះឯងលាងអាចន៍ងូតទឹកអោយខ្ញុំឡើងម៉ោក៏ខ្ញុំដុះលាងខ្អែលអោយទៅណាស់ដេកនៅទៅណាស់..

កៈ មើលថែប្តីរហូត...

ខៈ
ដល់តាខ្ញុំថៃយ៉ាងមិចដល់តែខ្ញុំដេកទៅយល់សប់ឃើញយល់សប់ថាគេហៅខ្ញុំថាអឺមីណមណ៎ក...មើលណែហានមីណមឯងខ្ញុំក៏ថាចុះហានឯណាគេថានេះៗកន្លែងអូនឯងនៅខ្ញុំអើតមើលញ៉ុមថាអូខ្ពស់ខ្លាំងម្លេះនៅដល់ទៅលើមេឃឯណោះមិនធ្លាក់ស្លាប់ហើយអ្ហា៎ស...គេថាអត់ធ្លាក់ទេណោក...ឡើងម៉ោឡើងមកមើលម៉ោដល់ទៅញ៉ុមឡើងក៏ឃើញអូ...លោកអើយ..ក្នុងព្រះធម៌គេមិនអោយនិយាយទេគឺអត់មានថ្មមួយប៉ុនតាផ្ទះរង្វើរង្វើមួយៗមានសុទ្ធតែមាន់សំឡីពីមុខផ្ទះដាំសុទ្ធតែផ្កាដល់តែខ្ញុំទៅសួរតាអាចារទៅក៏តាអាចារថាមីនាងឯថៃប្តីបានល្អហើយនាងថៃម្តាយបានល្អទៅគេអោយនាងឯងនិងឯងឃើញទីកន្លែងនាងឯងរស់នៅ...ចា៎ដល់តារួចរាល់អស់ទៅដល់តាប្តីងាប់ទៅក៏នាំកូននិងឯងទៅរ

កទៅអោយមួយនៅមើលផ្ទះទៅមួយទៀតចេញទៅរកទៅ...ប៉ុនអាធំអាបងនោះម្លោះមិនអោយវាទៅរៀនក៏វាទៅ...វាទៅតាវាទៅខំរៀនទៅតាវា..

កៈ គាត់អត់ឈប់ទេ...?

ខៈ អត់ឈប់...!

កៈ ចុះអញ្ចឹងកូនបងនិងរៀនដល់ណាដែរអ៊ុំ?

ខៈ ខ្ញុំមិនបានចាំទេ...

កៈ ចាំ...តែឥលូវនិងគាត់មានការងារល្អធ្វើហើយណោះអ៊ុំណោះ..!

ខៈ ទេអត់បានធ្វើទេមានអ៊ុយជិះទៅក៏ធ្វើការសំណង់នេះឯង...

កៈ ធ្វើការសំណង់...?

ខៈ

ចាំ...ប៉ុនតែអក្សរអីវាសរសេរបានហើយអង់គ្លេសអង់អីវាសរសេរបានហើយបើវាសរសេរបានមាននៃថាវាចេះ.......

កៈ ចាំ...ចុះកូនឯទៀតម្លោះអ៊ុំពួកគាត់ប្រកបមុខរបរអីគេដែរ?

ខៈ ធ្វើសំណង់ទាំងអស់គ្នាតាំងបងទាំងប្អូននិងឯង...

កៈ អ៎...ធ្វើការសំណង់ការងារធ្ងន់ណាស់អ៊ុំអើយ...

ខៈ ចាំស...!

កៈ ចាំមើលតែចាស់ទៅចុកដៃចុកជើង...! ពិបាក

ខៈ ចុះដឹងធ្វយ៉ាងមិចកូនបើយើងវាជំណាក់កាលយើងវាពិបាកនោះឯង...!

កៈ

ចុះអ៊ុំអត់ធ្លាប់គិតថាចង់អោយពួកគាត់រកស៊ីមុខរបរណាមុខរបរលក់ដូរដូចអ៊ុំកាលពីអ៊ុំនៅ....

ខ៖ លក់អីណាបើយើងវាអត់មានទុននោះ..អត់មានទុនអត់មានដីនៅនេះនៅដីគេតើ...

ក៖ ជួលគេអ្វោះអ៊ុំ?

ខ៖ ទេ...សុំគេនៅគេអោយនៅ...

ក៖ សុំគេនៅអ្វេណោះអ៊ុំ?

ខ៖
ចាំ...ដល់ទៅគេចិត្តល្អទៅក៏គេហៅមកនៅទៅ..គេអត់យកលុយយកកាក់ទេកូនអោយតែដឹងឃើញរឿងនិងខ្ញុំឈឺចាប់ណាស់...សព្វថ្ងៃខ្ញុំឈឺចាប់និងបងប្អូនណាស់ឈឺចាប់ដូចថាខ្ញុំវាអត់ដឹងគេដល់ប៉ុនណោះបើដឹងគេដល់ប៉ុនណោះខ្ញុំទុកអោយងាប់អស់អោយជាប់គុកជាប់ច្រវ៉ាក់ជំនាន់អាពតអត់ឃ្លានងាប់អស់កាលជំនាន់អាពតមានតែខ្ញុំនេះឯងគ្រប់គ្រងលួចទាំងប៉ុន្មានម៉ោបំបិទមុខបំបិទមាត់គេម៉ោអោយប្អូនស៊ីដល់ម៉ោអញ្ចេះទៅគេធ្វើយើង មិនដឹងគុណមិនដឹងអានន្តទៅអញ្ចឹងបានថាវាយ៉ាប់...នឹកឃើញ

ក៖
ចាំ...អ៊ុំចុះដូចជាតើអ៊ុំចាំឈ្មោះយាយតាខាងម្ដាយទេថាតើគាត់មានឈ្មោះយាយអីតាអីខ្លះ...?

ខ៖ ចាំចាំ..ឈ្មោះយាយលាប់តានូ......

ក៖ និងយាយតាខាងម្ដាយណោះអ៊ុំ?

ខ៖ ចាំ...! យាយតាខាងម្ដាយ!

ក៖ ចុះយាយតាខាងឪពុកវិញ?

ខ៖ ឪពុកនោះ...ឈ្មោះកុងតោណោក...កុងតោម៉ាយឿម.....

ក៖ ចុះអ៊ុំដូចជាមានសាច់ញាត្តិអីដែរនៅក្រៅប្រទេសដែរទេអ៊ុំ?

ខ៖ អត់មានទេកូន...!

ក៖ ចាំ..អត់មានទេណោះអ៊ុំណោះ!

ខ៖ អត់មានទេ៎...

ក៖ អ៎..ចា៎!

ខ៖ មានប៉ុន្តែថាមិនដឹងគេងាប់អស់មិនដឹងគេរស់...!

ក៖ អញ្ចឹងម្អោះអ៊ុំ?

ខ៖ ចា៎...! មានប៉ុនមិនដិងគេងាប់ក៏រស់!

ក៖ អ្នកណាគេបានទៅអ៊ុំ?

ខ៖ ណោក...ក្មួយខ្មោចជិក...! ក្មួយទេ

ក៖ អ៎..ក្មួយគាត់ការប្តីទៅឬក៏គាត់ទៅធ្វើការឬក៏គាត់ទៅលេង?

ខ៖ អត់ទេបាក់ជំនាន់នោះជំនាន់អាពតនេះឯងគេចេញជំនាន់អាពត...

ក៖ គាត់ឈ្មោះអីដែរអ៊ុំ អ៊ុំចាំទេ?

ខ៖
ណោក...ម្តាយវាងាប់អស់ឪពុកងាប់អស់ហើយនៅតែកូនទេអាទាងអាទេងចេះឯងអ៊ុយ
មិនដឹងគេទៅនៅឯណាខ្លះខ្លះថានៅស្រុកបារាំងខ្លះថានៅឯណាអីចិនមិនដឹងនៅឯណា
...!

ក៖ អ៊ុំអត់ដឹងអត់លឺដំណឹងទាំងអស់បាត់ដំណឹង...!

ខ៖ លឺតែថាគេនៅប៉ុនតែថាមិនដែរឃើញគេម៉ោ.....

ក៖ ចា៎...អ៊ុំដូចជាកាលសម័យអាពតតើអ៊ុំអាយុដែរអ៊ុំ?

ខ៖ កាលជំនាន់អាពតខ្ញុំសាម...

ក៖ អូ...អ៊ុំអាយុច្រើនណា៎..កំពុងតែពេញកំលាំងគេប្រើហើយអ៊ុំ...!

ខ៖ អូស...វៃកេជីទាល់តែងាប់!

កះ វែកដីទាល់តែងាប់អ្នេសអ៊ុំ?

ខះ សើច...វែក...វែកអត់បាយអត់ទឹកស៊ីតែបបរ..!

កះ អញ្ចឹងម្លោះអ៊ុំ?

ខះ និងហើយវាប្រើយោរយៅណាស់ជំនាន់អាពតនោះ...!

កះ អូ...ចាំ..អ៊ុំចុះតើអ៊ុំអាចប្រាប់ពិពណ៌នាអំពីជំនាន់អាពតនិងបានទេ
ថាគេអោយយើងធ្វើការមិចខ្លះព្រលឹមឡើង?

ខះ ធ្វើការមិចខ្លះកូន..! គេអោយវែកដី ...នោះហើយព្រលឹមឡើងគេអោយទៅវែកដី..

កះ យើងក្រោកព្រលឹមឡើងគេអោយទៅវែកដី...

ខះ
វែកដី...អស់ពីវែកដីទៅខែស្រូវគេអោយស្ទូងស្រូវច្រូតស្រូវដាំជំឡុងប៉ុនណោះឯងមាន
ធ្វើអីប៉ុនណោះឯង!

កះ យើងអ្នកធ្វើអីណោះអ៊ុំណោះ?

ខះ ចាំ...ស្រេចតែគេប្រើយើង!

កះ
ចាំ...អ៊ុំចុះដូចជាអាពាហ៍ពិពាហ៍របស់អ៊ុំអ្នាសតើអ៊ុំស្រលាញ់គ្នាដោយចិត្តនិងចិត្តឬក៏ឪពុ
កម្តាយជាអ្នករៀបចំអោយ?

ខះ ទេ...! ខ្ញុំការត្រឹមត្រូវរបស់ខ្ញុំ...!

កះ ចាំ...អ៊ុំស្រលាញ់គ្នាដោយខ្លួនឯងឬក៏ឪពុកម្តាយរៀបចំអោយ?

ខះ ទេ...ខ្ញុំមិនបានស្រលាញ់ទេខ្ញុំមិនដែរស្គាល់ទេឪម៉ែអោយក៏យកទៅ...!

កះ ឪពុកម្តាយអ៊ីណោះអ៊ុំគាត់អ្នករៀចំអោយ?

ខះ ចាំ..នោះឯង។

កៈ ចាំចុះអ៊ុំចាំទេពេលនិងអ៊ុំប្រហែលជាបានថ្លៃជំនូនប៉ុន្មានដែរទៅអ៊ុំ? ថ្លៃជំនូនអីណាស់អ៊ុំ?

ខៈ កាលនិងគេចាយអង្គរមិនដឹងប៉ុន្មានចូលស្រុកម៉ោ!

កៈ ពេលនិងលុយមិនសូវ.......

ខៈ ពេលនិងមានលុយអ៊ុយចាយ...ចាយអង្គរនិង! ចឹងមកចងដៃក៏អង្ករនិងស្រូវ..មិនដឹងទេកូនអើយភ្លេចហ៉ោស!

កៈ ចឹងអ៊ុំចាំទេអ៊ុំរៀនបានកម្រិតណាដែរអ៊ុំ?

ខៈ អូយ...ខ្ញុំបានរៀនតិចណាស់កូនអើយ...!

កៈ កាលនិងថ្នាក់ទីប៉ុន្មានដែរទៅអ៊ុំ?

ខៈ មិនដឹងថ្នាក់អាទិនិងថ្នាក់ទីប៉ុន្មាន?

កៈ ទីបីណោះអ៊ុំណោះ?

ខៈ អាទិនិងមិនដឹងទីប៉ុន្មាន?

កៈ កាលនិងអ៊ុំរៀពី ក ខ ឬ ក៏អីអ៊ុំ?

ខៈ ទេ...រៀនស្រៈយើងធម្មតា!

កៈ ប្រហែលជាថ្នាក់ទីមួយបើមិនអញ្ចឹងថ្នាក់ទីមតេយ្យហើយណោះអ៊ុំណោះ?

ខៈ ចាំ...! ប៉ិនថាយើងរៀជំនាន់និងរៀនបានតិចតែយើងមើលដាច់មើលឈ្មោះបានសរសេរបាន...!

កៈ ចាំ..នេះបើអ៊ុំភ្នែកភ្លឺអ៊ុំមើលអក្សរបានទេ?

ខៈ ភ្នែកភ្លឺអីបើមើលមិនឃើញកូន...!

កៈ ចាំ...បើពាក់វ៉ែនតា! ចុះអ៊ុំកាលនៅរៀអ៊ុំរៀននៅសាលាណាអ៊ុំចាំទេ?

ខៈ សាលាភ្នំក្រោម.........

កៈ សាលាភ្នំក្រោមណោះអ៊ុំណោះ?

ខៈ ចាំ...និងហើយ

កៈ អ៎...ចាំកាលអ៊ុំរៀនអ៊ុំមានបានរៀនជាប់លាប់ទេអ៊ុំពេលនិង?

ខៈ អឺ..រវល់ក៏ឈប់ទៅអត់មានអាណាមើលបងមើលប្អូន...!

កៈ អ៎...ដោយសារប្អូនអ៊ុំឈប់ដែរណោះអ៊ុំណោះ?

ខៈ ឈប់...!

កៈ យើងត្រូវការមើលប្អូន ...!

ខៈ ចាំ...!

កៈ ឪពុកម្ដាយទៅរកស៊ីណោះអ៊ុំណោះ?

ខៈ និងឯង ខ្មោចជិកខ្ញុំគាត់ទៅថ្លឹងស្រូវម៉ែខ្ញុំទៅថ្លឹងស្រូវទៅមានណាគេនៅផ្ទះ..

កៈ

ចាំ..ចង់ដឹងថាជីវិតរបស់អ៊ុំតាំងពីក្មេងរហូតដល់អ៊ុំចាស់ចំណាស់នេះអញ្ចឹងតើអ៊ុំមានការផ្លាស់ប្ដូរហើយឬនៅដូចថាកាលពីមុនពីបាកឥលូវស្រួលហើយឬក៏ពីមុនស្រួលតែឥលូវវាពិបាកអញ្ចឹងអឺណាំអ៊ុំ?

ខៈ បើមិនលំបាកយ៉ាងមិចចាស់ទៅវារឹតតែលំបាកឡើង...

កៈ ចាស់ទៅវារឹតតែលំបាកឡើង...អ្ហោះអ៊ុំ?

ខៈ និងហើយ...!

កៈ វាពិបាក.....

គះស្រួលអីអូនអើយវេទនាចុះមើលមើសគាត់មានដីអ៊ុយនៅ...

ខះ វាលំបាកតារហូតនិងឯង.....

គះ វាលំបាកណាស់ជីវិតគាត់......

កះ អញ្ចឹងធូរធារជាងនេះណោះអ៊ុំណោះ?

ខះ ចា៎..នោះឯង

កះ តែឥលូវយើង..

ខះ វេទនាណាស់......

កះ វេទនាណោះអ៊ុំ..! ចា៎ចុះផ្ទះនេះនៅប៉ុន្មាននាក់ដែរអ៊ុំ?

ខះ ប្រាំពីរនាក់...!

កះ ប្រាំពីរនាក់..! កេងទំរាបនៅនេះរ្អោះអ៊ុំ?

ខះ អឹស...បណ្ដោយទទឹងហើយ...ពញ្រៀតហើត!

កះ
ចា៎..ចុះអ៊ុំដូចជា!ឥលូវយើងបង្វែអារម្មណ៍វិញម្ដាអ៊ុំសួរថាតើមុខម្ហូបីដែរអ៊ុំចូលចូលចិត្តកាលនៅពីក្មេងអ្វីណាស់អ៊ុំ?

ខះ
អូយ...នាងអើយមិនដឹងជាចូលចិត្តអ៊ុយទេអានោះយើងចេះធ្វើខ្លួនយើងសព្វថ្ងៃចប់ហើយវាអត់ឃ្លាន...!

កះ អូ...ពេលចាស់ទៅលេងឃ្លានអស់?

ខះ និងហើយ អូយ..ចាស់ទៅហុកណាស់កូន!

កះ ចុះកាលពីអ៊ុំនៅក្មេងអ៊ុំចូលចិត្តក្រៀមក្រោះឬក៏បែបសម្លរ...?

ខ៖ អូ...ធម្មតាអត់ចេះរើស!

ក៖ អត់ចេះរើសទេណោះអុំ?

ខ៖ ចាំ..!

ក៖ អចាំចុះអុំកាលនៅពីក្មេងអីអុំចូលចិត្តស្តាប់បទចម្រៀងទេ?

ខ៖ ទេមានចម្រៀងអីស្តាប់នៅជំនាន់នោះអ្ហោះ..!

ក៖ កាលបែកអាពតម៉ោវិញហើយអីណាស់អុំ!

ខ៖ នោះឯង មិនមានអុយស្តាប់ទេកូនអើយ...

ក៖ ចុះឥលូវនិងសព្វថ្ងៃនិងអុំមានស្តាប់អីដេសអុំ?

ខ៖ ទេមានអុយស្តាប់ទេ!

ក៖ អត់ស្តាប់អីទេណោះអុំណោះ!

ខ៖ ចា...ស្តាប់អីក៏មិនចូល..

ក៖ ចាំ..ចុះអុំចេះស្តាប់ធម៌តេសអុំ?

ខ៖ ចាំ..តាយប់ឡើងសូត្រធម៌ដេកទៅ..

ក៖ ចុះតើអុំមានជំនាញអ្វីដែរតវេនពីឪពុកម្តាយម៉ោទេ?

ខ៖ អត់....!

ក៖ អត់មានទេណោះអុំណោះ?

ខ៖ ចា..អត់!

ក៖ មានតែជំនាញមួយគឺរកស៊ីណោះអុំ?

ខ៖ ចាំ...

កៈ ចាំដោយសារអ៊ុំកូនចិន!
ចុះអ៊ុំអាចចែកចាយមកកាន់ក្មួយទាក់ងទៅនិងអ៊ឹចថាតើដូចជាពេលដែរអ៊ុំរកស៊ីម៉្យាងអញ្ចឹងតើវាជួបទុក្ខលំបាកអីខ្លះហើយអ៊ុំធ្វើការអីផ្សេងទៀតជួបទុក្ខលំបាកអីខ្លះទៀតដូចថាតើរឿងរ៉ាវអីដែលអ៊ុំធ្លាប់ឆ្លងកាត់ម៉ោចឹងណាស់?

ខៈ
អឺស...លំបាកសព្វតែមុខកូនរែកនំកណ្តាលក្តៅមិចថាមិនលំបាក...ហូរញើសដូចទឹកនោះរួចចាក់បាញ់ឆេរនៅតែនិងភ្លើងមានរឿងអីថាមិនលំបានបើមុខរបរស្អីតែលំបាកទាំងអស់និង..មានរឿងអីថាមិនវេទនា

កៈ យាយឯងរែកចុកស្មាអស់ហើយ..!

ខៈអូស...ដាក់ប៉ុកចុះទៅដកដង្ហើមឡើងអង្គឹសវាធូន់នោះ..

កៈ អ៊ុំធ្លាប់លក់នំបញ្ចុកទេ?

ខៈ លក់..!

កៈ លក់សព្វគ្រប់ហើយមើលទៅបង្អែមនំបញ្ចុកនំបញ្ជេរអីទាំងអស់..!
ចាំអញ្ចឹងនំសព្វគ្រប់អីអ៊ុំចេះធ្វើអស់ហើយមើលទៅ?

ខៈ ចេះ..!

កៈ នំអាកោអីៗ!

ខៈ និងហើយចុះធ្វើចុងភៅការគេក៏ចេះ !

កៈ អូ...!

ខៈ ចុះបើដើរលេងរួចនោះ..

កៈ ចាំ...! ចឹងធ្លាប់ឆ្លងកាត់រឿងរ៉ាវច្រើនណាស់មែនទេអ៊ុំ?

ខៈ ច្រើនណាស់កូនអើយកុំអោយនិយាយ...

កៈ ពិសេសគឺនៅពេលដែលថា ប្ដីរបស់យើងធ្លាប់...អ៊ឹកដែលគេហៅថាអ្នកឧបត្ថម្ភនៅក្នុងគ្រួសារហើយសុខៗគាត់ស្រាប់តែទៅពិការភាពអញ្ចឹងយើងជាប្រពន្ធពិបាកណាស់ណោះអ៊ុំណោះ?ដែលថាពេលខ្លះយើងដើរតួជាម្ដាយផងជាឪពុកផងទៀតហើយយើងត្រូវចំណាយកំលាំងមើលប្ដីយើងទៀត ហើយយើងពិបាក គឺប្រឈរមុខនិងទុក្ខធំម៉ងនិងអ្នាស...

ខៈ ពិបាកណាស់ក្មួយអើយ...!

កៈ ចុះដូចជាអ៊ុំធ្លាប់ឆ្លងកាតនូវទុក្ខលំបាកច្រើនអ៊ីណាំអ៊ុំតើអ៊ុំមានពាក្យពេចន៍អីផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយអ៊ីណាំអ៊ុំដូចជាពួកកូនចៅៗអ៊ុំកូនៗអ៊ុំអញ្ចឹងអីណាស់...?

ខៈ ផ្ដាំយ៉ាងមិចថាកូនរាល់តាថ្ងៃថាកូនអើយម៉ែជាគំរូហើយអោយខំទៅទាន់កំលាំងនៅមាន...ប្រយ័ត្នតែចាស់ទៅវេទនា...

កៈ ចា...!

ខៈ ថារាល់តាថ្ងៃនិងឯងកូនទាំងប្រុសទាំងស្រីអើឯងខំទៅហើយកុំអោយចាយវាយធំកុំអោយដើរលេងច្រើនយប់ព្រលុប ហើយយើងជយខ្លួនយើងរួចសឹមយើងជួយគេយប់ព្រលុបឡើងស៊ីបាយទឹករួចហើយក៏ចូលដេកទៅមើលកូនចៅសន្តប់ជួយហើយយើងដេកទៅទុកកំលាំងតស៊ូតទៀតថាអញ្ចេះឯងបើគេមិនតាមក៏អត់ទៅ។

កៈ ចាំ...!

ខៈ មិនដឹងធ្វើមិច?

កៈ ចុះដូចជា...ការសិក្សាវិញអ៊ីណាស់អ៊ុំតើអ៊ុំគិតថាការសិក្សាមានសារសំខាន់ទេ?

ខ៖
អឺ...មានអ៊ុយកូនការសិក្សាវាសំខាន់ហើយប៉ុនតែថាគេមិនគិតមិនធ្វើមិនដឹងធ្វើយ៉ាងមិច?

ក៖
ចុះចំពោះកូនចៅជំនាន់ៗក្រោយៗដែលកំពុងតែសិក្សាចឹងតើអ៊ុំមានពាក្យពេចន៍អ្វីផ្ដែផ្ដាំទៅកាន់ពួកគាត់ទេ?

ខ៖
ទេប្រដៅអញ្ចេះឯងថាកូនអើយខំរៀនកុំអោយសូវដើរលេងតាកូនឯងដើរលេងទៅវាអស់ចេះហើយ...!

ក៖ អស់ចេះហើយ...ណោះអ៊ុំណោះ?

ខ៖ នុងឯង...! ខំរៀនទៅចៅឯងដើរលេងពេកចឹងមិចនិងចេះ..!

ក៖
ចុះបើសិនជាបងប្អូនរបស់អ៊ុំដែលថាកំពុងតាស្ដាប់នូវពាក្យពេចន៍របស់អ៊ុំអ្នាស...តើអ៊ុំមានពាក្យផ្ដែផ្ដាំទៅកាន់គាត់បងប្អូនបង្កើតរបស់អ៊ុំអ្នាស?

ខ៖ ផ្ដាំអាមិច...ផ្ដាំអីក៏ដែលថាគេបានទេ..!

ក៖ ចាំ..!
ចុះឥលូវនិងបើសិនជាគេបានស្ដាប់លឺនូវអ៊ុំនិយាយអីណាស់ចឹងតើអ៊ុំមានអ្វីនិយាយទៅកាន់ពួកគេចឹងអ្នាស?

ខ៖ ទេខ្ញុំមិនបាច់និយាយអីទៅកាន់គេតេស
និយាយគេមិនខ្លាចយើងគេមិនស្ដាប់យើង...

ក៖ អ់..អញ្ចឹងអ្ហោះអ៊ុំ?

ខ៖ ចាំ...!

គ៖ ញ៉ុមឃើញតាគាត់លំបាកតែម្នាក់គាត់ទេតាំងពីខ្ញុំដឹងក្តីម៉ោ
អ៊ូយ..គាត់វែកនំលក់ព្រឹកល្ងាច..

ក៖ ចា៎...អញ្ចឹងអ៊ុំមានតែប៉ុននិងទេណោះអ៊ុំ?

ខ៖ និងឯងមានតែប៉ុននិងឯងកូន...

ក៖
ចា៎អញ្ចឹងដូចជាពួកយើងសូមជូនពរអោយអ៊ុំវិញដូចថាក្នុងឱកាសដែលអ៊ុំបានចំណាយពេលវេលាមួយដែលថាអ៊ុំអនុញ្ញាតអោយចៅសំភាសន៍អ៊ុំស្រីដែលជាការសំភាសន៍របស់អ៊ុំស្រីទាក់ទងទៅនិងជីវប្រវត្តិរបស់អ៊ុំអញ្ចឹងអ៊ឺណាស់អ៊ុំ...អញ្ចឹងសូមជូពរអោយអ៊ុំបើសិនជាអ៊ុំកំពុងតែមានជំងឺអីសូមអោយអ៊ុំជាណា៎អ៊ុំណា៎...

ខ៖ សាធូបសាធូប...

ក៖
ហើយបើសិនជាក្នុងករណីដែលកូនរបស់អ៊ុំកំពុងធ្វើការអញ្ចឹងសូមអោយគាត់មានសុវត្តិភាពក្នុងការងាររបស់គាត់...

ខ៖ ចា៎សចា៎...!

ក៖
ហើយរកទទួលទានមានបានយកមកចិញ្ចឹមគ្រួសារអញ្ចឹងអ៊ឺណា៎អ៊ុំហើយអោយជួបអ្នកដែលជាជំនួយសូមអោយគេចុះមកជួយអ៊ុំណា៎អ៊ុំ...

ខ៖ ចា៎...

ក៖
ហើយសូមអោយអ៊ុំរឹងមាំហើយប្រឹងប្រែងខ្លួនឯងដែរហើយក៏ដូចជាព្យាយាមដើម្បីអភ័យទោសទៅកាន់អ្នកដទៃដែលតែងតែធ្វើអោយយើងពិបាកអ៊ឺណា៎អ៊ុំ...

ខ៖ នោះឯង...!

កៈ

ដោយសារតែអ៊ុំធ្លាប់ឆ្លងកាត់ច្រើនអញ្ចឹងក៏អ៊ុំទទួលបានបទពិសោធន៍ក្នុងជីវិតអ៊ុំបានភ្លក់គ្រប់រសជាតិទាំងអស់មកហើយចាំ..អញ្ចឹងដូចជាចៅមានតែប៉ុននិងតែសុំការអនុញ្ញាតពីអ៊ុំស្រីដើម្បីដាក់សំលេងអ៊ុំស្រីចូលទៅក្នុងគេហទំព័ររបស់ពូកយើងដើម្បីអោយកូនៗនិងកូនចៅជំនាន់ក្រោយដែលគេអាចបានស្តាប់លឺអំពីជីវប្រវត្តិរបស់អ៊ុំស្រីអឺណាំ...អ៊ុំស្រីណាំ...

ខៈ ចាំ...!

កៈ

ហើយពួកយើងដូចជាសុំការអនុញ្ញាតដើម្បីដាក់ទាំងរូបថតនិងសំលេងរបស់អ៊ុំផងដែរណះអ៊ុំណះ?

ខៈ ចាំ......!

កៈ ហើយពួកយើងមានតែប៉ិននិងហើយសូមជំរាបលាអ៊ុំស្រី...!

ខៈ ចាំ...ថតទៅ.....!